សួស្តី នៅក្នុងរូបភាពនេះគឺយើងនឹងនិយាយអំពីការទិញអាវយឺត។ អញ្ចឹងការទិញអាវយឺត ដោយជាទូទៅ យើងជាទូទៅ យើងតែងតែស្លៀកសម្លៀកបំពាក់ ឬក៏ពាក់ខោអាវផ្សេងៗ នៅពេលដែលយើងចេញដំណើរទៅធ្វើការ ឬក៏នៅផ្ទះ អញ្ចឹងពេលខ្លះខោអាវរបស់យើងចាស់ ខោអាវរបស់យើងចាស់ ឬក៏ចង្អៀត ដូច្នេះយើងត្រូវការអាវថ្មីដើម្បីចេញទៅក្រៅ ឬក៏ដើម្បីពាក់ ដើម្បីឲ្យល្អមនឹងខ្លួនយើង ដែលជាក់ស្តែងនៅក្នុងរូបភាពនេះ គឺយើងនឹងនិយាយអំពីការទិញអាវយឺត។

ដោយយើងឃើញនៅក្នុងរូបភាពទី ១ នៅក្នុងរូបភាពទី ១ យើងឃើញមានបុរសម្នាក់ ដែលគាត់មានវ័យប្រហែលជា ២០ ឆ្នាំ គាត់ពាក់អាវយឺតពណ៌ស ដៃខ្លី ហើយនៅក្នុងរូបភាពនេះ យើងឃើញថាគាត់កំពុងតែសម្លឹងមើលអាវរបស់គាត់ ហើយយកដៃទាំងពីរចាប់ទាញអាវរបស់គាត់ ដោយគាត់គិតថាប្រហែលជាអាវនោះតូចពេក ឬក៏ចង្អៀតពេកសម្រាប់គាត់ ដែលឥឡូវគាត់ធំហើយ ដូច្នេះអាវចាស់ពីមុនគឺរាងចង្អៀតសម្រាប់គាត់ ដោយគាត់ពាក់ទៅមិនសូវស្រួលខ្លួន ឬក៏គាត់ពាក់ទៅគឺមើលឃើញខើច ដោយសារតែអាវនោះវាតូចពេក អញ្ចឹងនៅក្នុងរូបភាពនេះ គឺយើងឃើញគាត់កំពុងតែគិតទៅដល់អាវថ្មីមួយ អញ្ចឹងគាត់គិតទៅដល់អាវមួយ ដែលជាអាវយឺតដែរ ប៉ុន្តែពណ៌លឿង អញ្ចឹងគាត់ចង់បានអាវយឺតថ្មីមួយសម្រាប់ពាក់ ដោយសារតែអាវយឺតដែលគាត់កំពុងតែពាក់ គឺវាតូចពេក ឬក៏ចង្អៀតខ្លួនគាត់ពេក អញ្ចឹងគាត់គិតចង់ទិញអាវយឺតពណ៌លឿងដៃខ្លីមួយសម្រាប់ពាក់នៅពេលថ្ងៃក្រោយទៀត ដូច្នេះហើយគាត់ក៏សម្លឹងមើលអាវរបស់គាត់យ៉ាងយកចិត្តទុកដាក់ អញ្ចឹងគាត់នឹងទៅទិញអាវថ្មីមួយទៀត។

បន្ទាប់មកទៀតរូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញថា បន្ទាប់ពីគាត់គិតទៅដល់អាវយឺតថ្មីមួយទៀតហើយ អញ្ចឹងគាត់គិតទៅដល់អាវយឺតថ្មី ដែលគាត់ចង់បានហើយ គាត់ក៏បានទៅជួបនឹងមិត្តស្រីរបស់គាត់។ អញ្ចឹងពួកគេទាំងពីរនាក់ក៏បានពិភាក្សាគ្នា ដោយយើងឃើញមិត្តស្រីរបស់គាត់ មានវ័យប្រហែលនឹងគាត់ដែរ ឬក៏មានវ័យស្របាលគ្នានឹងគាត់ ដោយមានវ័យប្រហែលជា ២០ ឆ្នាំ។ យើងឃើញមិត្តស្រីរបស់គាត់ក៏ពាក់អាវយឺតពណ៌សដៃខ្លីដែរ ប៉ុន្តែមិត្តស្រីរបស់គាត់គឺមានសក់វែង ហើយសក់មិត្តស្រីរបស់គាត់ហ្នឹង គឺចងទៅខាងក្រោយទាំងអស់ គាត់ចងសក់ទៅខាងក្រោយ អញ្ចឹងគាត់ឈរទល់មុខជាមួយនឹងបុរសម្នាក់នោះ ដែលជាមិត្តប្រុសរបស់គាត់ ដែលបុរសម្នាក់នោះ គាត់បាននិយាយអំពីអាវយឺតមួយ អញ្ចឹងគាត់ប្រាប់ទៅមិត្តស្រីរបស់គាត់ថា គាត់ចង់បានអាវយឺតថ្មី ដោយសារតែអាវយឺតចាស់របស់គាត់ហ្នឹងគឺចង្អៀតនឹងខ្លួនគាត់ពេក ពិបាកនឹងពាក់។ ដោយយើងឃើញនៅក្នុងរូបភាពនេះ គឺពួកគេកំពុងតែពិភាក្សាគ្នា ដោយបុរសម្នាក់នោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់បានលើកដៃស្ដាំឡើង ហើយក្ដាប់ដៃ [...] យកមេដៃចង្អុលមកខ្លួនគាត់ ដោយគាត់កំពុងតែនិយាយប្រាប់មិត្តស្រីរបស់គាត់ថា គាត់ចង់បានអាវយឺតមួយដើម្បីពាក់ ដែលល្មមនឹងខ្លួនគាត់ មិនតូចពេក ឬក៏មិនធំពេក។

បន្ទាប់មកទៀតរូបភាពទី ៣ នៅក្នុងរូបភាពទី ៣ យើងឃើញថា ពួកគេ បន្ទាប់ពីពិភាក្សាគ្នាហើយ អញ្ចឹងជួនជាថ្ងៃនោះជាថ្ងៃសម្រាកផង ឬក៏ជាពេលល្ងាច ឬក៏ពេលយប់ដែលពួកគេចេញពីធ្វើការ អញ្ចឹងពួកគេអត់ធ្វើការទៀតទេ ដូច្នេះពួកគេក៏បានដើរមកផ្សារដើម្បីទិញខោអាវ ដើម្បីរកមើលអាវយឺតថ្មីសម្រាប់បុរសម្នាក់នោះ។ អញ្ចឹងយើងឃើញនៅក្នុងរូបភាពនេះ ពួកគេក៏បានដើរមកដល់ផ្សាររាត្រីមួយ ដែលជាទូទៅផ្សាររាត្រីគឺជាផ្សារមួយ ដែលយើងបើកនៅពេលយប់តែប៉ុណ្ណោះ អញ្ចឹងពេលថ្ងៃគឺផ្សាររាត្រីអត់បើកទេ ដែលផ្សាររាត្រី គឺបើកតែពេលយប់ អញ្ចឹងអាចបើកចាប់ពីម៉ោង ៥ ល្ងាច រហូតដល់ម៉ោង ១១ យប់ ឬក៏ម៉ោង ១២ យប់។ អញ្ចឹងនៅក្នុងផ្សាររាត្រីគឺយើងលក់ដូចផ្សារពេលថ្ងៃដែរ។ អញ្ចឹងមានផ្សារខ្លះគេបើកពេលថ្ងៃ ផ្សារខ្លះគេបើកពេលយប់ អញ្ចឹងផ្សារពេលយប់យើងហៅថាផ្សាររាត្រី ដោយសារតែពេលយប់យើងអាចហៅម្យ៉ាងទៀតបានថារាត្រី ពេលរាត្រី។ អញ្ចឹងពេលរាត្រី គឺ ឬក៏ពេលយប់ហ្នឹងគឺអត់មានព្រះអាទិត្យទេ គឺមានតែព្រះចន្ទ។ ដែលជាក់ស្ដែងយើងឃើញនៅក្នុងរូបភាពនេះគឺមានព្រះចន្ទមួយដែលកំពុងតែរះ ហើយពួកគេទាំងពីរនាក់ក៏បានដើរមកដល់ផ្សាររាត្រីនោះ ដោយយើងឃើញមានតូបជាច្រើនកំពុងតែលក់ដូរ ដែលយើងឃើញមាន តូបនោះគឺមានស្តង់ផងដែរ យើងហៅថាស្តង់ ដែលជារោងមួយសម្រាប់ដាក់អីវ៉ាន់លក់ដូរ។ ដែលយើងឃើញនៅខាងមុខពួកគេទាំងពីរនាក់ គឺមានបុរសម្នាក់ គាត់ឈរនៅក្រោមឆត្រមួយ នៅខាងមុខ នៅខាងក្រោយកន្លែងលក់ដូររបស់គាត់ ដែលតូបនោះអាចលក់ជាស្រោមជើង ឬក៏អាចលក់ជាឆ្នាំងដី ឬក៏ក្អមជាដើម ដែលយើងឃើញគាត់មានព្យួរខោផងដែរ។ អញ្ចឹងបានន័យថាគាត់ក៏មានលក់ខោអាវផង គាត់លក់ជាស្រោមជើងផង ឬក៏លក់ជាឆ្នាំងផងដែរ។ ដែលនៅក្នុងផ្សាររាត្រីគឺលក់ច្រើនប្រភេទ មានទំនិញច្រើនប្រភេទដើម្បីលក់ អញ្ចឹងពេលខ្លះ ពេលយើងត្រូវការទិញទំនិញ នៅពេលដែលយើងចេញពីធ្វើការពេលល្ងាច អញ្ចឹងផ្សារខ្លះគេបិទអស់ហើយ ដូច្នេះយើងអាចទៅរកទំនិញនៅផ្សាររាត្រីបាន យើងអាចទិញទំនិញនៅផ្សាររាត្រីបានតាមតម្រូវការ។ អញ្ចឹងក្បែរតូបរបស់បុរសម្នាក់នោះ ដែលបុរសដែលពាក់មួកនោះ គឺយើងឃើញមានកន្លែងមួយទៀតដែលគេលក់ខោអាវ។ ដែលយើងឃើញនៅទីនោះគឺមានគេព្យួរអាវលក់ជាច្រើន អញ្ចឹងគេមានព្យួរអាវលក់ ដោយអាវគេព្យួរទៅនឹងស្មាអាវ ឬក៏ទំពក់ព្យួរខោអាវ។ យើងហៅថាទំពក់ព្យួរខោអាវ ឬក៏ស្មាអាវក៏បានដែរ។ អញ្ចឹងគេប្រើដែកសម្រាប់ព្យួរអាវដាក់ទៅលើរបារដែកមួយ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងរបារដែកនោះ យើងឃើញមានពីរជាន់ ដែលជាន់ទីមួយព្យួរអាវ ក៏ព្យួរអាវ
ជាន់ទីពីរក៏ព្យួរអាវផងដែរ ហើយនៅជិតរបារដែកនោះគឺមានអ្នកលក់ម្នាក់ផងដែរ
ដែលជាអ្នកលក់ស្រី។ អញ្ចឹងអ្នកលក់ហ្នឹងគឺគាត់ពាក់អាវស ខោសជើងវែង
ហើយគាត់ឈរជិតខោអាវរបស់គាត់ដែលកំពុងតែលក់ អញ្ចឹងបានន័យថាគាត់ជាអ្នកលក់
ហើយគាត់កំពុងតែរង់ចាំស្វាគមន៍អតិថិជនរបស់គាត់ដើម្បីចូលទៅទិញ។
ដោយយើងឃើញបុរសម្នាក់ដែលមានវ័យ ២០ ឆ្នាំនោះជាមួយនឹងមិត្តស្រីរបស់គាត់
ក៏បានដើរមកដល់ផ្សាររាត្រីដើម្បីរកអាវផងដែរ។

បន្ទាប់មកទៀតរូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញថា
បន្ទាប់ពីពួកគេបានដើរមកដល់ផ្សាររាត្រីហើយ ពួកគេក៏បានមករកតូបខោអាវ។
អញ្ចឹងយើងឃើញរូបភាពទី ៤ នេះ ពួកគេក៏បានចូលមកដល់ហាងលក់ខោអាវមួយកន្លែង
ដែលហាងលក់ខោអាវនោះ យើងឃើញមានរបារព្យួរខោអាវចំនួនពីរថ្នាក់
ដែលយើងឃើញមានអាវជាច្រើននៅលើរបារនោះកំពុងតែព្យួរ
ដោយបុរសម្នាក់នោះបានចូលទៅជួបជាមួយនឹងអ្នកលក់
អញ្ចឹងអ្នកលក់ក៏បានណែនាំអាវជាច្រើនទៅដល់បុរសម្នាក់នោះដើម្បីល។
អញ្ចឹងយើងឃើញមានអាវស អាវពណ៌ខៀវ អាវពណ៌ស អាវពណ៌លឿងជាច្រើន
កំពុងតែព្យួរនៅលើរបារដែក។ ដោយគេព្យួរនឹងស្មាអាវ ឬក៏ទំពក់ព្យួរខោអាវ។
ដោយយើងឃើញនៅក្នុងរូបភាពនេះ បុរសដែលមានវ័យ [២៥] ២០ ឆ្នាំនោះ
គាត់បានឈរទល់មុខនឹងអ្នកលក់ ដែលអ្នកលក់គឺជាស្រី គឺជាស្ត្រី
ដូច្នេះគាត់ពាក់អាវយឺតពណ៌សដៃខ្លី ហើយសក់របស់គាត់ត្រឹមស្មារបស់គាត់ ឬក៏ត្រឹមករបស់គាត់។
អញ្ចឹងអ្នកលក់គាត់កាត់សក់ខ្លី ហើយគាត់កំពុងតែលើកដៃស្ដាំឡើង
ដើម្បីចង្អុលទៅអាវប្រាប់ទៅដល់បុរសម្នាក់នោះ។
អញ្ចឹងបុរសម្នាក់នោះគាត់អាចមើលអាវដែលអ្នកលក់ណែនាំបាន ព្រោះអ្នកលក់ជាអ្នកណែនាំអាវ
ថាអាវប្រភេទណាសាច់ក្រណាត់ល្អ អាវប្រភេទណាទើបតែនាំចូល
ដូច្នេះអ្នកលក់នឹងណែនាំទៅដល់អតិថិជន។ ដោយបុរសម្នាក់នោះគាត់អាចមើលតាមអ្នកលក់
ហើយជ្រើសរើសពណ៌អាវទៅតាមតម្រូវការរបស់គាត់ដែលគាត់ចូលចិត្ត។

បន្ទាប់មកទៀតរូបភាពទី ៥ រូបភាពទី ៥ អ្នកលក់ក៏បានណែនាំអាវយឺតពណ៌ខៀវមួយទៅដល់គាត់។
អញ្ចឹងរូបភាពទី ៥ នេះ គាត់ក៏បានយកអាវយឺតពណ៌ខៀវដែលនៅជាប់ស្មាអាវនោះមកល
អញ្ចឹងគាត់បានយកអាវនោះមកពិនិត្យយ៉ាងយូរមុននឹងគាត់ល
ដោយគាត់ពិនិត្យនៅលើស្មាអាវនោះ។ ដោយយើងឃើញនៅក្នុងរូបភាពនេះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ហាក់ដូចជាពេញចិត្តនឹងអាវយឺតមួយនោះផងដែរ ដោយគាត់មានទឹកមុខញញឹម ហើយគាត់ចាប់កាន់អាវយឺតនោះដោយដៃទាំងពីររបស់គាត់។ អញ្ចឹងគាត់កំពុងតែត្រួតពិនិត្យអាវរបស់គាត់នោះ ឬក៏អាវយឺតដែលអ្នកលក់ឲ្យគាត់នោះ ថាតើវាស្អាតដែរឬទេ អញ្ចឹងគាត់ពិនិត្យតាំងពីថ្នេរនិងតាំងពីសាច់ក្រណាត់ជាដើម ដោយគាត់ពិនិត្យយ៉ាងយកចិត្តទុកដាក់បំផុត ព្រោះថាពេលខ្លះអាវ ប្រសិនបើយើងអត់ពិនិត្យទេ វាអាចនឹងធ្វើឲ្យយើងខុស ព្រោះពេលខ្លះថ្នេររបស់វាគឺអត់ជាប់ល្អទេ។ អញ្ចឹងថ្នេរអត់ជាប់ល្អ អញ្ចឹងវាអាចធ្វើឲ្យឆាប់រហែក ឬក៏សាច់ក្រណាត់អត់ល្អ ពាក់ទៅយើងអត់ស្រួលខ្លួននោះទេ ដូច្នេះមុននឹងសម្រេចចិត្តទិញអាវ យើងត្រូវពិនិត្យឲ្យបានហ្មត់ចត់ ព្រោះថាប្រសិនបើយើងទិញខុសគឺវាពាក់អត់ស្រួល ហើយវាឆាប់រហែកទៀតផង។ អញ្ចឹងជាក់ស្តែងរូបភាពទី ៥ នេះ បុរសម្នាក់នោះ គាត់បានយកអាវនោះមកពិនិត្យយ៉ាងយកចិត្តទុកដាក់មុននឹងគាត់លូ។

បន្ទាប់មកទៀតរូបភាពទី ៦ នៅក្នុងរូបភាពទី ៦ យើងឃើញថា បន្ទាប់ពីបុរសម្នាក់នោះគាត់បានពិនិត្យអាវគាត់យ៉ាងយកចិត្តទុកដាក់រួចមក គាត់ក៏បានយកអាវនោះមកលូ។ អញ្ចឹងគាត់បានយកអាវនោះមកលូ ដោយគាត់ យើងឃើញគាត់បានដោះអាវរបស់គាត់ដែលកំពុងតែពាក់ចេញ។ អញ្ចឹងអម្បាញ់មិញគាត់ពាក់អាវយឺតពណ៌ស ដើម្បីមកទិញ ប៉ុន្តែនៅពេលដែលគាត់លូ គាត់ត្រូវដោះអាវយឺតពណ៌សនោះចេញ ហើយពាក់ជំនួសដោយអាវយឺតពណ៌ខៀវ ដែលគាត់កាន់អម្បាញ់មិញចូល។ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញគាត់បានស៊កក្បាលចូលទៅក្នុងកអាវមុន អញ្ចឹងក្បាលរបស់គាត់ស៊កចូលទៅក្នុងកអាវ បន្ទាប់មកគាត់យកដៃឆ្វេង ដៃស្តាំរបស់គាត់ដាក់ចូលទៅក្នុងដៃអាវដើម្បីពាក់។ អញ្ចឹងគាត់យកដៃឆ្វេងរបស់គាត់ដាក់ចូលក្នុងដៃអាវរួចរាល់ហើយ បន្ទាប់មកគាត់យកដៃឆ្វេងរបស់គាត់ម្ខាងទៀត ដៃស្តាំគឺគាត់ដាក់ចូលក្នុងដៃអាវហើយ បន្ទាប់មកគាត់យកដៃឆ្វេងលូកចូលទៅក្នុងដៃអាវម្ខាងទៀតដើម្បីពាក់ អញ្ចឹងដៃឆ្វេងរបស់គាត់កំពុងតែលើកឡើងលើ ដើម្បីដាក់ចូលក្នុងដៃអាវ ហើយដៃស្តាំកំពុងតែទាញខ្លួនអាវដើម្បីទម្លាក់ចុះក្រោម អញ្ចឹងពេលខ្លះពាក់អាវយឺតគឺរៀងពិបាកបន្តិច ដោយសារតែវាអត់មានឡេវទេ អាវយឺតអត់មានឡេវទេ ដូច្នេះយើងត្រូវពាក់ក្បាលមុន បន្ទាប់មកយើងដាក់ដៃទាំងពីររបស់យើងចូលទៅក្នុងដៃអាវដើម្បីពាក់វា ហើយពេលខ្លះខ្លួនអាវគឺវាអត់ធ្លាក់ចុះទេ ដោយវានៅរមូលនៅខាងលើ ដូច្នេះដើម្បីឲ្យខ្លួនអាវធ្លាក់ចុះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

យើងត្រូវតែចាប់ទាញខ្លួនអាវទម្លាក់ចុះក្រោម។ ជាក់ស្តែងនៅរូបភាពទី ៦ នេះ បុរសម្នាក់នេះ គាត់កំពុងតែទាញខ្លួនអាវ ដើម្បីទម្លាក់ចុះក្រោម ដើម្បីបិទបាំងខ្លួនរបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញថា បន្ទាប់ពីគាត់លហើយ គាត់ក៏បានចេញពីបន្ទប់ផ្លាស់សម្លៀកបំពាក់មកក្រៅ អញ្ចឹងជាទូទៅកន្លែងលក់ខោអាវនីមួយៗ គេតែងតែមានបន្ទប់ផ្លាស់សម្លៀកបំពាក់មួយ ដើម្បីឲ្យអតិថិជនរបស់គេលខោអាវ ដែលបន្ទាប់ពីលហើយ អតិថិជនរបស់ពួកគេនឹងចេញមកក្រៅដើម្បីសួរអ្នកលក់ថាសមដែរឬទេ។ អញ្ចឹងជាក់ស្តែងរូបភាពនេះគឺ បុរសម្នាក់នោះ គាត់បានចូលក្នុងបន្ទប់ដើម្បីផ្លាស់ខោអាវ បន្ទាប់មក បន្ទាប់ពីផ្លាស់ខោអាវរួចមក គាត់ក៏បានចេញមកក្រៅដើម្បីមើលកញ្ចក់ អញ្ចឹងអ្នកលក់ក៏បានយកកញ្ចក់មួយមកឲ្យបុរសនោះឆ្លុះ អញ្ចឹងគាត់ឆ្លុះកញ្ចក់ ដោយគាត់មើលទៅក្នុងកញ្ចក់ ដើម្បីឃើញរូបភាពរបស់គាត់ជាមួយនឹងអាវ។ ដែលនៅក្នុងរូបភាពនេះយើងឃើញបុរសម្នាក់នោះ គាត់បានពាក់អាវពណ៌ខៀវអម្បាញ់មិញដែលគាត់ល អញ្ចឹងគាត់លអាវថ្មីពណ៌ខៀវនោះ ហើយគាត់ចេញមកក្រៅដោយយកដៃទាំងពីរច្រត់ចង្កេះ ហើយមានទឹកមុខញញឹម ដែលគាត់ពេញចិត្តនឹងខោអាវនោះផងដែរ ដែលគាត់មានអារម្មណ៍ថាពេញចិត្តផងដែរ ដោយគាត់ស្រឡាញ់អាវនោះ បន្ទាប់មកអ្នកលក់ គាត់បានយកកញ្ចក់មួយដើម្បីឲ្យបុរសនោះឆ្លុះ ដោយអ្នកលក់គាត់បានដៃម្ខាងកាន់កញ្ចក់ និងដៃម្ខាងទៀតចង្អុលទៅកញ្ចក់ ដើម្បីឲ្យបុរស[...] ប្រាប់ទៅបុរសម្នាក់នោះឆ្លុះកញ្ចក់។ អញ្ចឹងនៅក្នុងរូបភាពនេះ គឺគេលខោអាវ បន្ទាប់ពីលហើយ គេឆ្លុះកញ្ចក់មើលថាតើអាវនោះសមនឹងគេដែរឬទេ។

បន្ទាប់មកទៀតរូបភាពទី ៨ នៅក្នុងរូបភាពទី ៨ យើងឃើញថា បន្ទាប់ពីគាត់បានឆ្លុះកញ្ចក់ បុរសម្នាក់នោះ គាត់ក៏បានប្រែប្រួលទឹកមុខ អញ្ចឹងបានន័យថាគាត់អត់សូវពេញចិត្តនឹងអាវនោះទេ ដោយសារតែអាចអាវនោះវាតូចពេក ឬក៏ធំពេក មិនល្មមនឹងខ្លួនគាត់ អញ្ចឹងរូបភាពនេះយើងឃើញ បុរសនោះ គាត់ប្រែប្រួលទឹកមុខ ដោយគាត់មិនសូវជាសប្បាយចិត្តនឹងអាវនោះ ដោយគាត់ឆ្លុះមើលកញ្ចក់ ដោយភ្នែករបស់គាត់សម្លឹងទៅកញ្ចក់ ហើយដៃរបស់គាត់ចាប់ទាញសាច់អាវមក អញ្ចឹងគាត់កំពុងតែចាប់ទាញសាច់អាវ ដែលយើងឃើញរូបភាពនៅក្នុងកញ្ចក់នោះ គឺគាត់កំពុងតែទាញអាវ បានន័យថាអាវនោះប្រហែលជាធំជាងខ្លួនគាត់ពេក គឺមិនល្មមនោះទេ គឺបានន័យថាអាវនោះរលុង ដូច្នេះគាត់អត់ពេញចិត្តទេ ដោយសារតែការទិញអាវគឺយើងអត់ពាក់អាវធំពេកទេ ប្រសិនបើពាក់អាវធំពេក នោះវាធ្វើឲ្យយើងអត់ស្អាតនោះទេ។ អញ្ចឹងយើងមើលទៅអត់ស្អាត ដូច្នេះយើងអត់ពាក់អាវធំជាងខ្លួនទេ គឺយើងពាក់អាវដែលល្មមនឹងខ្លួនយើង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយសារតែនៅពេលដែលយើងពាក់អាវដែលល្មមនឹងខ្លួនយើង គឺមើលទៅយើងឃើញស្អាត ហើយសង្ហាជាងមុន ដូច្នេះប្រសិនបើយើងពាក់អាវធំពេកគឺមើលទៅយើងឃើញចាស់ ហើយអត់សង្ហាទេ អញ្ចឹងរូបភាពនេះ គឺបុរសម្នាក់នោះ គាត់កំពុងតែឆ្លុះកញ្ចក់ ដោយអ្នកលក់ គាត់កំពុងតែកាន់កញ្ចក់ដើម្បីឲ្យបុរសម្នាក់នោះឆ្លុះ ហើយយើងឃើញកញ្ចក់របស់អ្នកលក់ គឺមានចងខ្សែផងដែរ អញ្ចឹងដើម្បីកុំឲ្យបាត់កញ្ចក់អ្នកលក់ក៏បានចងខ្សែដើម្បីព្យួរ អញ្ចឹងអ្នកលក់ព្យួរកញ្ចក់នោះដោយចងខ្សែ ហើយនៅពេលណាដែលអ្នកលក់ចង់ឆ្លុះកញ្ចក់ អ្នកលក់នោះ អតិថិជនចង់ឆ្លុះកញ្ចក់ អ្នកលក់គាត់គ្រាន់តែយកកញ្ចក់នោះមកកាន់ គឺ ហើយឲ្យអ្នកទិញគាត់ឆ្លុះគឺជាការស្រេច។

បន្ទាប់មកទៀតរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញថា បន្ទាប់ពីបុរសម្នាក់នោះ គាត់ឆ្លុះកញ្ចក់ហើយ គាត់អត់ពេញចិត្តនឹងអាវនោះទេ ដោយអាវនោះធំពេក ដូច្នេះគាត់ក៏បានដោះអាវនោះចេញ អញ្ចឹងគាត់ក៏បានចូលមកក្នុងបន្ទប់ផ្លាស់សម្លៀកបំពាក់ម្តងទៀត ដោយគាត់ចូលមកក្នុង[ផ្លាស់]បន្ទប់ផ្លាស់សម្លៀកបំពាក់ បន្ទាប់មកគាត់ក៏បានដោះអាវពណ៌ខៀវនោះចេញ អញ្ចឹងយើងឃើញនៅក្នុងរូបភាពនេះ គាត់កំពុងតែចាប់ទាញកអាវ គាត់យកដៃស្តាំរបស់គាត់ គាត់យកដៃឆ្វេង គាត់យកដៃឆ្វេងរបស់គាត់ចាប់ទាញកអាវឡើង អញ្ចឹងដើម្បីដោះអាវយឺតគឺយើងប្រើដៃឆ្វេង ឬក៏ដៃស្តាំរបស់យើង ចាប់ទាញកអាវ ដើម្បីឲ្យផុតពីក្បាល អញ្ចឹងនៅពេលដែលដោះអាវ គឺយើងត្រូវដោះក្បាលចេញមុន បានន័យថាយើងត្រូវយកកអាវចេញពីក្បាល ចេញ យើងចេញមុន ដោយយើងចាប់ទាញឡើង បន្ទាប់មកយើងលើកដៃទាំងពីរឡើងលើ។ ដោយយើងឃើញជាក់ស្តែងនៅក្នុងរូបភាពទី ៩ នេះ បុរសម្នាក់នោះ គាត់បានយកដៃឆ្វេងរបស់គាត់ ចាប់ទាញកអាវខាងក្រោយឡើងលើដើម្បីឲ្យផុតក្បាល ដើម្បីឲ្យកអាវនោះផុតក្បាល បន្ទាប់មកគាត់លើកដៃស្តាំឡើង គាត់លើកដៃស្តាំឡើង ដើម្បីឲ្យងាយស្រួលក្នុងការដោះដៃចេញពីដៃអាវនោះ។ ដោយគាត់ ដោយសារតែអាវធំពេក ដូច្នេះគាត់អត់ពាក់អាវនោះទេ អញ្ចឹងគាត់អត់ទិញអាវនោះទេ ដោយគាត់ដោះឲ្យអ្នកលក់វិញ អញ្ចឹងគាត់ចូលក្នុងបន្ទប់ផ្លាស់សម្លៀកបំពាក់ ដើម្បីដោះអាវខៀវនោះចេញ ហើយពាក់អាវពណ៌សរបស់គាត់ ដែលពាក់មកពីផ្ទះអម្បាញ់មិញវិញ។ អញ្ចឹងហើយនៅពេលដែលយើងទិញអត់ត្រូវ គឺយើងអត់យកទេ គឺយើងគ្រាន់តែដោះអាវដែលយើងលនោះទៅឲ្យអ្នកលក់វិញ ព្រោះថាពេលដែលយើងល គឺគេអត់គិតលុយយើងទេ ដើម្បីឲ្យសាកជាមួយនឹងខ្លួនថាតើអាវនោះសមជាមួយនឹងយើងដែរឬទេ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១០ នៅក្នុងរូបភាពទី ១០ យើងឃើញថា បន្ទាប់ពីគាត់ដោះអាវនោះប្រគល់ទៅឲ្យអ្នកលក់វិញហើយ គាត់ក៏ចេញក្រៅមក ខាងក្រៅមកក្នុងហាងវិញ បានន័យថាគាត់ចេញពីបន្ទប់ផ្លាស់សម្លៀកបំពាក់មកវិញ អញ្ចឹងនៅពេលដែលគាត់ចេញមកវិញ គាត់ក៏បានបន្តរកអាវនៅក្នុងហាងនោះទៀត ព្រោះពេលខ្លះអាវតែមួយគឺយើងអត់ដឹងថាសមនឹងខ្លួនយើងឬអត់នោះទេ ដូច្នេះគឺនៅក្នុងហាងមានអាវច្រើន អញ្ចឹងប្រសិនបើអត់ល្អមមួយ យើងអាចរកអាវផ្សេងទៀត ដើម្បីលបាន។ ដែលជាក់ស្តែងនៅក្នុងរូបភាពទី ១០ នេះ បន្ទាប់ពីគាត់ចេញមកពីបន្ទប់ផ្លាស់សម្លៀកបំពាក់វិញ យើងឃើញថាមិត្តស្រីរបស់គាត់ ក៏បានរកអាវមួយដើម្បីឲ្យគាត់។ អញ្ចឹងមិត្តស្រីរបស់គាត់ គាត់ក៏បង្ហាញអាវលឿងមួយ អាវយឺតពណ៌លឿងមួយទៅដល់បុរសម្នាក់នោះ។ អញ្ចឹងបុរសម្នាក់នោះ គាត់ក៏បានគិត ដែលយើងឃើញនៅក្នុងរូបភាពនេះ គឺមិត្តស្រីរបស់គាត់កំពុងតែកាន់អាវយឺតពណ៌លឿងដៃខ្លីមួយបង្ហាញទៅបុរសម្នាក់នោះ អញ្ចឹង[ពួក] គាត់បង្ហាញដោយភាពញញឹម ព្រោះថាមិត្ត នារីម្នាក់នោះ ប្រហែលជាគាត់ដឹងចិត្តបុរសម្នាក់នោះថាតើគាត់ចូលចិត្តអ្វី [ឬក៏]ចូលចិត្តអាវពណ៌អី ដូច្នេះហើយទើបគាត់បង្ហាញអាវយឺតមួយនោះ បុរសម្នាក់នោះក៏ញញឹម ហើយក៏ចង្អុលមកខ្លួនឯងថាគាត់ចូលចិត្តអាវមួយនោះ ដូច្នេះគាត់ក៏យកអាវមួយនោះទៅលទៀត។ អញ្ចឹងនៅក្នុងរូបភាពទី ១០ នេះ គឺមិត្តស្រីរបស់គាត់ជាអ្នករើសអាវយឺតឲ្យគាត់ដើម្បីពាក់ ឬក៏ដើម្បីល ព្រោះថានៅពេលដែលគាត់រើសខ្លួនឯង គឺបុរសម្នាក់នោះ គាត់រើសអត់ត្រូវនោះទេ បានន័យថាគាត់រើសខ្លួនឯងគឺគាត់រើសពណ៌ខៀវ ក៏ប៉ុន្តែអាវពណ៌ខៀវគឺអត់ល្អមនឹងខ្លួនគាត់នោះទេ ដូច្នេះមិត្តស្រីរបស់គាត់ ក៏បានជ្រើសរើសអាវពណ៌លឿងមួយទៀត ដើម្បីឲ្យបុរសម្នាក់នោះល ថាតើត្រូវនឹងខ្លួនគាត់ដែរឬទេ។

បន្ទាប់មកទៀតរូបភាពទី ១១ នៅក្នុងរូបភាពទី ១១ បន្ទាប់ពីគាត់បានទទួលអាវយឺតពណ៌លឿងនោះពីមិត្តស្រីរបស់គាត់ហើយ អញ្ចឹងគាត់បានទទួលពីមិត្តស្រីរបស់គាត់ហើយ បុរសម្នាក់នោះ គាត់ក៏បានចូលទៅក្នុងបន្ទប់ផ្លាស់សម្លៀកបំពាក់ម្តងទៀត ដើម្បីធ្វើការផ្លាស់ខោអាវ ដើម្បីលអាវយឺតពណ៌លឿងនោះ។ អញ្ចឹងដូចពីមុនដែរ ដូចពីមុន គឺគាត់ដោះអាវសរបស់គាត់ចេញ ហើយគាត់ពាក់អាវយឺតពណ៌លឿងនោះចូល ហើយបន្ទាប់មកគាត់ក៏បានចេញពីបន្ទប់ផ្លាស់សម្លៀកបំពាក់មកក្រៅ ដើម្បីឆ្លុះកញ្ចក់ម្តងទៀត។ អញ្ចឹងនៅក្នុងរូបភាពនេះយើងឃើញអ្នកលក់ គាត់ក៏បានយកកញ្ចក់ ដើម្បីឲ្យបុរសម្នាក់នោះ គាត់ឆ្លុះកញ្ចក់មើលថាតើអាវនោះសមនឹងខ្លួនគាត់ដែរឬទេ ? អញ្ចឹងម្តងនេះ បុរសម្នាក់នោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់មានទឹកមុខញញឹម ហើយគាត់ពេញចិត្តនឹងអាវនោះខ្លាំងណាស់ ដោយអាវដែលមិត្តស្រីគាត់រកឲ្យគាត់នោះគឺល្មមនឹងខ្លួនគាត់តែម្ដង គឺមិនធំពេក ហើយក៏មិនតូចពេកដែរ។ អញ្ចឹងបុរសម្នាក់នោះឆ្លុះកញ្ចក់បណ្ដើរ ទាញសាច់អាវបណ្ដើរ ហើយគាត់ទឹកមុខគាត់ញញឹម ឬក៏សើចសប្បាយ ព្រោះគាត់អាចរកអាវដែលល្មមនឹងគាត់ ហើយជាពិសេសគឺពណ៌អាវដែលគាត់ចូលចិត្តទៀតផង។ អញ្ចឹងបុរសម្នាក់នោះគាត់ញញឹម ដូច្នេះនៅពេលដែលឃើញអតិថិជនញញឹម អ្នកលក់ក៏ញញឹមផងដែរ ព្រោះអតិថិជនស្រឡាញ់អាវគាត់ និងចូលចិត្តអាវគាត់ អញ្ចឹងអតិថិជននឹងទិញអាវរបស់គាត់។ ដូច្នេះអ្នកលក់ក៏សប្បាយចិត្តផងដែរ ហើយបុរសម្នាក់នោះ គាត់សប្បាយចិត្ត ដោយសារតែគាត់អាចរកអាវដែលល្មមនឹងខ្លួនគាត់បាន។

បន្ទាប់មកទៀតរូបភាពទី ១២ រូបភាពទី ១២ បន្ទាប់ពីបុរសម្នាក់នោះគាត់បានលអាវហើយឆ្លុះកញ្ចក់រួចរាល់ហើយ អញ្ចឹងគាត់ពេញចិត្តនឹងអាវនោះ ដូច្នេះគាត់ក៏បានមកឲ្យមិត្តស្រីរបស់គាត់មើលម្ដងទៀតផងដែរ។ ដោយអាវនោះជាអាវរបស់មិត្តស្រីគាត់រើសឲ្យ ដូច្នេះនៅពេលដែលគាត់ល គាត់ក៏បានមកបង្ហាញខ្លួនឲ្យមិត្តស្រីរបស់គាត់ឃើញថាតើមិត្តស្រីរបស់គាត់ពេញចិត្តដែរឬទេ? អញ្ចឹងនៅក្នុងរូបភាពនេះ គាត់ក៏បានដើរមកច្រត់ចង្កេះខាងមុខមិត្តស្រីរបស់គាត់ ហើយញញឹមទៅកាន់មិត្តស្រីរបស់គាត់ ដើម្បីបង្ហាញខ្លួនថាតើអាវនោះសមដែរឬទេ? អញ្ចឹងមិត្តស្រីរបស់គាត់ក៏បានលើកដៃពីរឡើង ដោយដៃទាំងសងខាងរបស់មិត្តស្រីរបស់គាត់លើកឡើង ហើយទឹកមុខរបស់មិត្តស្រីរបស់គាត់គឺភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះយើងឃើញថា អាវមួយនោះគឺសមនឹងខ្លួនរបស់បុរសម្នាក់នោះតែម្ដង គឺល្មម។ អញ្ចឹងនារីម្នាក់នោះ គាត់ក៏បានរំភើប ហើយក៏សប្បាយចិត្តយ៉ាងខ្លាំង ដោយសារតែគាត់អាចរើសអាវយឺតមួយ ដែលល្មមនឹងមិត្តប្រុសរបស់គាត់ អញ្ចឹងគាត់លើកដៃទាំងពីរឡើង ហើយសម្ដែងទឹកមុខភ្ញាក់ផ្អើល ដោយគាត់ពេញចិត្តអាវយឺតនោះយ៉ាងខ្លាំង ដូច្នេះពួកគេទាំងពីរនាក់គឺស្រឡាញ់អាវយឺតមួយនោះខ្លាំងណាស់ ដោយអាវយឺតមួយនោះគឺជាពណ៌ដែលមិត្តប្រុសរបស់គាត់ពេញចិត្ត ហើយល្មមនឹងមិត្តប្រុសគាត់តែម្ដង អញ្ចឹងបានន័យថានារីម្នាក់នោះ គឺគាត់ដឹងអំពីបុរសម្នាក់នោះថាតើទំហំខ្លួនគាត់ប៉ុណ្ណា ហើយគាត់ចូលចិត្តអ្វី ដូច្នេះទើបនារីម្នាក់នោះ គាត់បានយកអាវដែលល្មមនឹងខ្លួនបុរសម្នាក់នោះមកឲ្យបុរសម្នាក់នោះល។ អញ្ចឹងនៅក្នុងរូបភាពទី ១២ គឺពួកគេទាំងពីរនាក់គឺចូលចិត្តអាវនោះយ៉ាងខ្លាំង។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ បន្ទាប់ពីបុរសម្នាក់នោះគាត់បានបង្ហាញខ្លួន ឬក៏បង្ហាញអាវដែលគាត់លនោះទៅដល់មិត្តស្រីរបស់គាត់ហើយ មិត្តស្រីរបស់គាត់ពេញចិត្ត ដូច្នេះគាត់ក៏បានចូលទៅក្នុងបន្ទប់ផ្លាស់សម្លៀកបំពាក់ម្តងទៀត ហើយដោះអាវយឺតលឿងនោះចេញ និងពាក់អាវសដែលគាត់ពាក់មកពីផ្ទះចូលវិញ។ អញ្ចឹងទោះបីជាយើងពេញចិត្តក៏ដោយ ពេលខ្លះអាវទិញថ្មីគឺយើងអត់ពាក់ភ្លាមនោះទេ គឺយើងត្រូវតែខ្ចប់ដើម្បីយកទៅផ្ទះ និងដើម្បីពាក់ថ្ងៃក្រោយ។ អញ្ចឹងជាក់ស្តែងនៅក្នុងរូបភាពទី ១៣ នេះ គឺបុរសម្នាក់នោះ គាត់ក៏បានយកអាវដែលគាត់ទើបតែទិញនោះ មកឲ្យអ្នកលក់វិញ អញ្ចឹងគាត់យកមកឲ្យអ្នកលក់ ហើយប្រាប់ទៅអ្នកលក់ថាគាត់ទិញអាវមួយនេះ អញ្ចឹងគាត់ទិញអាវពណ៌លឿងមួយនេះ ដូច្នេះគាត់ឲ្យយក គាត់ឲ្យអ្នកលក់យកទៅខ្ចប់ឲ្យគាត់។ ដែលយើងឃើញនៅក្នុងរូបភាពទី ១៣ នេះ គឺបុរសម្នាក់នោះ គឺដៃឆ្វេងរបស់គាត់កាន់អាវ ដៃឆ្វេងរបស់គាត់កាន់អាវ ហើយដៃស្តាំរបស់គាត់ចង្អុលទៅអាវ ដោយគាត់ចង់បញ្ជាក់ប្រាប់អ្នកលក់ថាគាត់យកអាវមួយនេះ។ អញ្ចឹងអ្នកលក់គាត់ក៏បានយកដៃពីរដើម្បីទទួលអាវនោះ គាត់លើកដៃទាំងពីររបស់គាត់ឡើង ដើម្បីទទួលអាវពីបុរសម្នាក់នោះ ដើម្បីយកទៅខ្ចប់។

បន្ទាប់មកទៀតរូបភាពទី ១៤ រូបភាពទី ១៤ បន្ទាប់ពីអ្នកលក់បានទទួលអាវលឿងនោះពីបុរសម្នាក់នោះហើយ អ្នកលក់ក៏បានបត់អាវនោះយ៉ាងមានសណ្តាប់ធ្នាប់និងយ៉ាងស្អាត។ អញ្ចឹងគាត់គឺបានបត់អាវនោះយ៉ាងស្អាត ហើយចាក់ ដាក់ចូលទៅក្នុងថង់មួយ។ អញ្ចឹងក្នុងការទិញខោអាវគឺអ្នកលក់តែងតែបត់អាវដាក់ចូលទៅក្នុងថង់ ព្រោះថាប្រសិនបើអត់ដាក់ថង់ទេ គឺអាវនោះនឹងពិបាកនៅក្នុងការយួរ ហើយអាចប្រឡាក់អាវបាន អញ្ចឹងអាវ ដោយសារអាវជាអាវថ្មី ដូច្នេះគឺយើងអត់ត្រូវធ្វើឲ្យប្រឡាក់នោះទេ ដោយសារតែប្រសិនបើប្រឡាក់ អតិថិជននឹងមិនពេញចិត្តនោះទេ ដូច្នេះនារីនោះ អ្នកលក់ក៏បានបត់អាវនោះយ៉ាងស្អាត ហើយដាក់ចូលទៅក្នុងថង់ អញ្ចឹងនៅពេលដែលយើងដាក់អាវចូលទៅក្នុងថង់ គឺអតិថិជនងាយស្រួលយួរទៅផ្ទះ។ ម្យ៉ាងវិញទៀតវាអត់ធ្វើឲ្យអាវប្រឡាក់ទៀតផង។ អញ្ចឹងរូបភាពទី ១៤ គឺយើងឃើញថាអ្នកលក់ គាត់កំពុងតែខ្ចប់អាវនោះចូលទៅក្នុងថង់មួយ ដើម្បីឲ្យទៅអតិថិជនរបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥ យើងឃើញថា បន្ទាប់ពីអ្នកលក់គាត់បានខ្ចប់អាវហើយ អញ្ចឹងគាត់ក៏បានប្រគល់ថង់អាវនោះឲ្យទៅបុរស ដែលជាអ្នកទិញ ឬក៏ជាអតិថិជន អញ្ចឹងក្រោយពីបានទទួលថង់អាវ បុរសដែលជាអ្នកទិញនោះ គាត់ក៏បានប្រគល់លុយថ្លៃអាវទៅឲ្យអ្នកលក់ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញបុរសម្នាក់នោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ក៏បានកាន់លុយមួយចំនួនដែលជាថ្លៃអាវហុចទៅឲ្យអ្នកលក់ រីឯអ្នកលក់
គាត់ក៏បានទទួលលុយពីអ្នកទិញដោយទឹកមុខញញឹម។ អញ្ចឹងនៅក្នុងរូបភាពទី ១៥
គឺពួកគេទាំងពីរនាក់ គឺកំពុងតែសប្បាយរីករាយ ដោយសារតែបុរសម្នាក់នោះ
គាត់បានរកអាវដែលគាត់ស្រឡាញ់ ឬក៏រកអាវ រកបានអាវដែលគាត់ពេញចិត្តបាន ហើយអ្នកទិញ
រីឯអ្នកលក់វិញ គាត់សប្បាយចិត្ត ដោយសារតែគាត់បានលក់អាវដល់អតិថិជនរបស់គាត់ដាច់
អញ្ចឹងគាត់សប្បាយចិត្តដោយសារតែគាត់លក់ដាច់ ដូច្នេះពួកគេទាំងពីរនាក់
គឺសប្បាយចិត្តទាំងពីរនាក់ ដោយសារម្នាក់អាចទិញអាវបាន រីឯម្នាក់ទៀតគឺបានលក់អាវដាច់។
អញ្ចឹងរូបភាពទី ១៥ នេះ គឺបុរសម្នាក់នោះ
គាត់បានប្រគល់លុយថ្លៃអាវទាំងទឹកមុខញញឹមទៅឲ្យអ្នកលក់
ហើយអ្នកលក់ក៏បានទទួលយកលុយថ្លៃអាវនោះទាំងទឹកមុខញញឹមដូចគ្នា។

បន្ទាប់មកទៀតរូបភាពទី ១៦ នៅក្នុងរូបភាពទី ១៦ បន្ទាប់ពីពួកគេឲ្យលុយថ្លៃអាវរួចរាល់ហើយ
ពួកគេទាំងពីរនាក់ក៏បានដើរចេញពីហាងនោះ អញ្ចឹងរូបភាពនេះ គឺនារីដែលជាមិត្តស្រីនោះ
គាត់បានដើរខាងមុខ ហើយងាកមកខាងក្រោយដើម្បីនិយាយជាមួយមិត្តប្រុសរបស់ពួកគេ
របស់នាង។ អញ្ចឹងបុរសម្នាក់នោះគាត់ដើរខាងក្រោយ ហើយដៃរបស់គាត់គឺយួរថង់មួយ
ដែលជាថង់អាវគាត់ទើបតែទិញអម្បាញ់មិញ។ អញ្ចឹងបន្ទាប់ពីពួកគេបានទិញអាវរួចរាល់ហើយ
ពួកគេក៏បណ្ដើរគ្នាទៅកន្លែងផ្សេងទៀត ដើម្បីទៅញ៉ាំអាហារ ឬក៏ទៅញ៉ាំអ្វីផ្សេងៗ
ឬក៏ទៅទិញអីវ៉ាន់ដទៃទៀតដែលពួកគេត្រូវការ
ដោយសារតែពួកគេបានទិញអាវដែលពួកគេពេញចិត្តរួចរាល់ហើយ
ដូច្នេះនៅពេលដែលពួកគេបានទិញអាវដែលពួកគេស្រឡាញ់រួចរាល់ហើយ ពួកគេក៏បានចេញពីហាង
ដើម្បីទៅរកកន្លែងផ្សេងទៀត ដើម្បីទៅញ៉ាំអាហារ ឬក៏ទៅផ្ទះរបស់ពួកគេវិញ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.